

*សេចក្ដីផ្ដើម*

# **ក្នុងព្រះវត្តមានព្រះអង្គ**

## ការចំណាយពេលជាមួយព្រះ

មានពេលមួយបុរសម្នាក់បានសួរកូនប្រុសរបស់គាត់ ដោយបំណងល្អថា "តើកូនអធិស្ឋានមួយថ្ងៃប៉ុន្មានដង?" កូនប្រុសដែលមានអាយុ១៤ឆ្នាំម្នាក់នេះ បានញាក់ស្មា ហើយជម្រាបគាត់ថា "កូនមិនសូវអធិស្ឋានទេ"។

ពេលឮដូច្នេះ បុរសជាឪពុកមានការបារម្ភចំពោះកូន ក៏បានសួរទៀតថា "ហេតុអ្វីកូនមិនសូវអធិស្ឋាន?"

កូនគាត់ក៏បានឆ្លើយថា "កូនមិនសូវមានអីដែលត្រូវទូលសូមពីព្រះអង្គផង"។

ក្មេងជំទង់ម្នាក់នេះ បានឆ្លើយតប ដោយពាក្យសម្ដីដែលស្មោះត្រង់ទេ។ គ្រីស្ទបរិស័ទជាច្រើន មិនហ៊ាននិយាយប្រាប់អ្នកដទៃ ដោយត្រង់ៗដូចគាត់ទេ ថាពួកគេអធិស្ឋាន តែនៅពេលដែលខ្លួនចង់ទូលសូមអ្វីពីព្រះអង្គប៉ុណ្ណោះ។

ក្នុងទំព័របន្ទាប់ លោកដេននីស ហ្វីសស័រ( Dennis Fisher ) ដែលជាអ្នកនិពន្ធនៃអង្គការនំម៉ាណាប្រចាំថ្ងៃ នឹងលើកឡើងអំពីការលំបាកដែលយើងមានជាធម្មតាក្នុងការញែកពេលថ្វាយព្រះ។ ទន្ទឹមនឹងនោះ លោកក៏បង្ហាញនូវចំណុចសំខាន់ៗមួយចំនួន ជាជំនួយដល់យើង នៅពេលដែលយើងខិតខំអធិស្ឋាន អានព្រះបន្ទូល និងបម្រើអ្នកដទៃ។

## *អង្គការនំម៉ាណាប្រចាំថ្ងៃ*

# មាតិកា

*ទី១*

**បញ្ហា**……………………………………………………………………………..៥

*ទី២*

**ការរៀបចំខ្លួន**……………………………………………………………………១១

*ទី៣*

**ការអនុវត្តន៍**………………………………………………………………………១៧

*ទី៤*

**អត្ថប្រយោជន៍**……………………………………………………………………២៣

អ្នកគ្រប់គ្រងផ្នែកកែសម្រួលអត្ថបទ : J. R. Hudberg
រចនាក្របដោយ: Stan Myers
រូបភាពក្របដោយ: ©iStock.com / ImagineGolf
រចនាផ្នែកខាងក្នុងដោយ: Steve Gier
ប្រែសម្រួលជាភាសាខ្មែរ ដោយ : លោក ឯក សត្យា
បទគម្ពីរជាភាសាខ្មែរដកស្រង់ចេញពីព្រះគម្ពីរបរិសុទ្ធ ភាសាខ្មែរ បកប្រែចាស់ ឆ្នាំ១៩៥៤
ដោយការអនុញ្ញាតិ និងរក្សាសិទ្ធិដោយសមាគមន៍ព្រះគម្ពីរសកល។
រក្សាសិទ្ធិគ្រប់យ៉ាងដោយ: © 2015 ODB Ministries ( website: www.odb.org )
ចេញផ្សាយដោយ : ODB Cambodia ( email: cambodia@rbc.org, Tell: 087 233 907, website: http://khmer-odb.org, FB page : https://www.facebook.com/RBCCambodia, )
បោះពុម្ពដោយ: រោងពុម្ពហ្គ្រេស( Grace Printing House, Phnom Penh, Cambodia )



*ទី១*

# បញ្ហា

ព្រះគម្ពីរបានចែងថា បន្ទាប់ពីព្រះបានបង្កើតបុរសនិងស្រ្តីដំបូងហើយ ព្រះអង្គ "យាងក្នុងសួនច្បារនៅពេលថ្ងៃល្ងើយ"(លោកុប្បត្តិ ៣:៨)។ ព្រះអាទិករនៃចក្រវាល ទ្រង់មិនបានលាក់ព្រះភ័ក្ត្រព្រះអង្គ ពីមនុស្សដែលព្រះអង្គបានបង្កើតឡើយ ហើយក៏មិនបានឲ្យពួកទេវតាមកទំនាក់ទំនងជាមួយពួកគេ ជំនួសព្រះអង្គដែរ។ ផ្ទុយទៅវិញ ព្រះអង្គបានយាងចុះមករកអ័ដាំម និងនាងអេវ៉ា ដោយផ្ទាល់ ដើម្បីមានការប្រកបខាងវិញ្ញាណជាមួយអ្នកទាំងពីរ។

ត្រង់ចំណុចនេះ ព្រះដែលស្រឡាញ់ការប្រកបគ្នា ដែលបានដើរជាមួយអ័ដាំម និងនាងអេវ៉ា នៅពេលថ្ងៃល្ងើយ ព្រះអង្គក៏កំពុងតែឈោងព្រះហស្តមករកយើងម្នាក់ៗ ក្នុងពេលបច្ចុប្បន្នផងដែរ។ ដូចនេះ ការចំណាយពេលស្ងាត់ស្ងៀមជាមួយព្រះ ជាការចំណាយពេលជាមួយព្រះអង្គ ដើម្បីពិសោធនឹងព្រះវត្តមាន ការកម្សាន្តចិត្ត និងការដឹកនាំរបស់ព្រះអង្គ។ មានមនុស្សជាច្រើន ចង់មានពេលស្ងាត់ស្ងៀមដ៏មានន័យជាមួយព្រះអង្គ តែយើងពិបាកនឹងរកឱកាស ដោយសារបរិយាកាសនៅជុំវិញខ្លួនយើងមិនអំណោយផល។ ការអាក់ខាននេះ អាចនាំឲ្យយើងមានអារម្មណ៍ថា ខ្លួន

បានធ្វើខុសនឹងព្រះអង្គ ដោយមិនយកចិត្តទុកដាក់ចំពោះការចំណាយពេលផ្ទាល់ខ្លួនជាមួយព្រះអង្គ។ ប៉ុន្តែ បើសិនជាយើងវាស់វែងការលូតលាស់ខាងវិញ្ញាណរបស់យើង ដោយរាប់ចំនួនពេលដែលយើងបានជួបជាមួយព្រះអង្គ ក្នុងពេលមួយសប្តាហ៍នេះ នោះមានន័យថា យើងបានគិតខុសហើយ។ ចំណុចសំខាន់នៃការប្រកបជាមួយព្រះបន្ទូល គឺស្ថិតនៅត្រង់ចិត្តរបស់យើង មិនគ្រាន់តែជាការណាត់ពេលជួបជាមួយព្រះអង្គ តាមកាលវិភាគរបស់យើងប៉ុណ្ណោះទេ។

*__ពេលស្ងាត់ស្ងៀម__ ជាពេលដ៏ពិសេស ដែលយើងញែកចេញសម្រាប់សន្ទនាជាមួយព្រះ។ ពេលស្ងាត់ស្ងៀមច្រើនតែរាប់បញ្ចូលការអធិស្ឋាន ការអានព្រះគម្ពីរ និងការជញ្ជឹងគិតព្រះបន្ទូល។ ពេលស្ងាត់ស្ងៀមច្រើនតែធ្វើឡើងប្រចាំថ្ងៃ និងនៅពេលដ៏ជាក់លាក់ណាមួយ។*

កាលខ្ញុំនៅរៀននៅមហាវិទ្យាល័យ ក្នុងឆ្នាំទី២ ខ្ញុំមានការពិបាក ក្នុងការលត់ដំខ្លួន។ ខ្ញុំមានកិច្ចការជាច្រើនដែលត្រូវធ្វើ ហើយក៏មានការរំខានជាច្រើន ដែលបានប្រជែងយកពេលវេលាដែលខ្ញុំត្រូវប្រើសម្រាប់ធ្វើកិច្ចការដែលគ្រូដាក់ឲ្យៗទាន់ពេល និងសម្រាប់រៀនត្រៀមប្រលង។ ភាពមមាញឹកក្នុងការរស់នៅ តែងតែនាំឲ្យខ្ញុំជំនួសកិច្ចការណាមួយ ដោយកិច្ចការមួយទៀតដែលខ្ញុំគិតថាសំខាន់ជាង ឬធ្វើឲ្យខ្ញុំមិនអើពើរទាល់តែសោះចំពោះកិច្ចការមួយចំនួន។ ពេលនោះ ខ្ញុំហាក់ដូចជាមិនបានសម្រេចកិច្ចការអ្វីសោះ មិនតែប៉ុណ្ណោះ ខ្ញុំថែមទាំងមានការពិបាក ក្នុងការរៀបផែនការ ដើម្បីធ្វើកិច្ចការផ្សេងៗផងដែរ។

មានពេលយប់មួយ បន្ទាប់ពីចប់ម៉ោងរៀនក្នុងថ្នាក់ ខ្ញុំក៏បានពិភាក្សាជាមួយសាស្ត្រាចារ្យរបស់ខ្ញុំ អំពីបញ្ហារបស់ខ្ញុំ។ គាត់បានណែនាំខ្ញុំ ឲ្យដាក់អាទិភាព ក្នុងកាលវិភាគប្រចាំថ្ងៃរបស់ខ្ញុំ។ ពេលខ្ញុំយកយោបលរបស់គាត់មកពិចារណា ព្រះក៏បានបណ្តាលចិត្តខ្ញុំ ឲ្យដាក់ពេលស្ងាត់ស្ងៀមជាមួយព្រះ ជាអាទិភាពសំខាន់បំផុតក្នុងថ្ងៃនីមួយៗ។ នោះហើយជាការអ្វីដែល "ខ្ញុំត្រូវធ្វើ" កុំឲ្យអាក់ខាន ទោះបីជាមានកិច្ចការជាច្រើនទៀត ដែលត្រូវធ្វើក្នុងថ្ងៃនីមួយៗក៏ដោយ។ ដើម្បីកុំឲ្យខានប្រកប

ជាមួយព្រះបន្ទូលព្រះអង្គជាប្រចាំថ្ងៃ ខ្ញុំក៏បានដាក់ផែនការថា ការប្រកបជាមួយព្រះបន្ទូល ជាកិច្ចការទីមួយ ដែលខ្ញុំត្រូវធ្វើរៀងរាល់ពេលព្រឹក។

ប៉ុន្តែ នៅថ្ងៃបន្ទាប់ ពេលខ្ញុំចាប់ផ្តើមអនុវត្តតាមការប្តេជ្ញាចិត្តដែលខ្ញុំទើបតែមានថ្មីៗ ការតាំងចិត្តនោះក៏បានអន់ខ្សោយទៅវិញ។ ខ្ញុំក៏បានយល់ថា ការចំណាយពេលជាមួយព្រះអង្គ ហាក់ដូចជាតម្រូវឲ្យមានការប្រឹងប្រែងខ្លាំងពេក ហើយមិនបានទទួលលទ្ធផលគ្រប់គ្រាន់ទេ។ ខ្ញុំគ្រាន់តែមិនមានអារម្មណ៍ក្នុងការប្រកបជាមួយព្រះបន្ទូលព្រះ។ ខ្ញុំក៏បានទូលថ្វាយព្រះអង្គ អំពីអារម្មណ៍របស់ខ្ញុំ។ ខ្ញុំទូលព្រះអង្គថា ខ្ញុំមានចិត្តតោះតើយ គឺមិនសូវជាចង់ចំណាយពេលជាមួយព្រះអង្គទេ។ ខ្ញុំបានសារភាពនៅចំពោះព្រះអង្គ អំពីចិត្តដែលខ្វះភាពឆេះឆួលនោះ ហើយបានអរព្រះគុណព្រះអង្គសម្រាប់ការអត់ទោសបាប ។



*ការចំណាយពេលស្ងាត់ស្ងៀមជាមួយព្រះ ជាការចំណាយពេលជាមួយព្រះអង្គ ដើម្បីពិសោធនឹងព្រះវត្តមាន ការកម្សាន្តចិត្ត និងការដឹកនាំរបស់ព្រះអង្គ។*

បន្ទាប់មក ខ្ញុំក៏បានសម្រេចចិត្តថ្វាយអារម្មណ៍របស់ខ្ញុំដល់ព្រះអង្គ។ ខ្ញុំបានទូលសូមព្រះអង្គ ឲ្យដកយកភាពអសកម្ម និងភាពតោះតើយចេញ ហើយប្រទានឲ្យខ្ញុំមានភាពឆេះឆួលឡើង។ ពេលដែលខ្ញុំកំពុងអានព្រះបន្ទូលសម្រាប់ប្រកបជាមួយព្រះបន្ទូលប្រចាំថ្ងៃ ខ្ញុំក៏បានអធិស្ឋានសូមឲ្យមានការផ្លាស់ប្រែដ៏ពិតក្នុងជីវិតខ្ញុំ។ ពេលខ្ញុំចាប់ផ្តើមអធិស្ឋាន អំពីគម្រោងដែលខ្ញុំត្រូវធ្វើ នៅពេលក្រោយ នៅថ្ងៃនោះ ខ្ញុំបានទូលព្រះអង្គ អំពីកិច្ចការដែលគ្រូដាក់ឲ្យខ្ញុំធ្វើនោះ ហើយសូមឲ្យព្រះអង្គប្រទានកម្លាំង ប្រយោជន៍ឲ្យខ្ញុំអាចធ្វើកិច្ចការនេះឲ្យអស់ពីលទ្ធភាព។

ពេលដែលខ្ញុំចាប់ផ្តើមធ្វើដំណើរទៅសាលា ខ្ញុំក៏ចាប់ផ្តើមមានអារម្មណ៍ថា មានកម្លាំងក្នុងខ្លួន និងមានអារម្មណ៍មូល ហើយដែលសំខាន់បំផុតនោះ គឺខ្ញុំមានការគ្រប់គ្រងពេលវេលាបានល្អ ដែលពីមុនខ្ញុំមិនអាចធ្វើបាន។ ពន្ទុះរបស់ខ្ញុំក៏បានឡើងខ្ពស់ជាមុខ ក្នុងឆមាសនោះ។ ព្រះអង្គបានឆ្លើយតបការអធិស្ឋានរបស់ខ្ញុំ។ ពេលខ្ញុំបន្តទូលសូមឲ្យព្រះអង្គជួយ ឲ្យខ្ញុំមានការប្តេជ្ញាចិត្តកាន់តែរឹងមាំ ក្នុងការចំណាយពេលជាមួយព្រះអង្គ ខ្ញុំក៏រកបានកម្លាំង ដែលខ្ញុំត្រូវការ។

គឺដូចដែលព្រះគម្ពីរអេសាយបានចែងថា "អស់អ្នកណាដែលសង្ឃឹមដល់ព្រះយេហូវ៉ាវិញ នោះនឹងមានកំឡាំងចំរើនជានិច្ច"(អេសាយ ៤០:៣១)។ ព្រះបន្ទូលសន្យា ដែលលោកហោរាបានថ្លែងទៅកាន់រាស្ត្រអ៊ីស្រាអែលនៅសម័យដើម ក៏ជាព្រះបន្ទូលសន្យា សម្រាប់យើង ក្នុងសម័យបច្ចុប្បន្នផងដែរ។ ក្នុងព្រះគម្ពីរដើមជាភាសាហេព្រើ ពាក្យថា មានកម្លាំងចម្រើនជានិច្ច គឺមានន័យថា "ជំនួសដោយកម្លាំងថ្មី ផ្លាស់ប្តូរកម្លាំងជាថ្មី បង្ហាញនូវភាពថ្មី ឬលូតលាស់ជាថ្មី"។ តែត្រង់ចំណុចនេះ យើងត្រូវដឹងថា ដើម្បីឲ្យបានកម្លាំងចម្រើនឡើង យើងត្រូវសង្ឃឹមដល់ព្រះ ដោយមានសកម្មភាព គឺមិនមែនអសកម្ម ដោយរង់ចាំទទួលផលតែមួយមុខនោះទេ។ មានន័យថា យើងត្រូវមានចិត្តចង់ធ្វើអ្វីម្យ៉ាង ដើម្បីឲ្យបានទទួលកម្លាំងមកពីព្រះ។ ព្រះអង្គមិនបានរំពឹងឲ្យយើង ដកកកាយរកកម្លាំងចិត្ត និងការប្តេជ្ញាចិត្ត ដែលនៅសេសសល់ក្នុងខ្លួនយើងនេះទេ។ ផ្ទុយទៅវិញ យើងត្រូវទូលសូមឲ្យព្រះអង្គប្រទានកម្លាំងរបស់ព្រះអង្គមកយើង និយាយរួម គឺសូមឲ្យព្រះអង្គប្រទានឲ្យយើងមានកម្លាំង។

## អ្នកដែលយើងត្រូវយកគំរូតាម

ពេលយើងស្វែងរកឱកាសចំណាយពេលជាមួយព្រះ តើយើងគួរយកគំរូតាមនរណា? តើមាននរណាដែលមានគំរូល្អជាងព្រះយេស៊ូវទៀតនោះ? ក្នុងអំឡុងពេលព្រះអង្គកំពុងបំពេញព្រះរាជកិច្ច ក្នុងលោកិយនេះ ព្រះវរបិតាបានអំណាចព្រះចេស្តារបស់ព្រះអង្គ។ ទោះបីជាព្រះអង្គជាព្រះមួយរយភាគរយក៏ដោយ ក៏ព្រះអង្គនៅតែត្រូវពឹងផ្អែកលើព្រះវរបិតា និងព្រះវិញ្ញាណបរិសុទ្ធដែលបានគង់សណ្ឋិតក្នុងព្រះអង្គ និងធ្វើការតាមរយៈព្រះអង្គ។ ជាក់ស្តែង យើងឃើញថា ព្រះអង្គពិតជាបានពឹងផ្អែកទៅលើព្រះវរបិតាមែន ដោយព្រះអង្គយាងទៅរកពេលស្ងាត់ស្ងៀមជាមួយព្រះវរបិតាតែអង្គឯង។ ព្រះគម្ពីរដំណឹងល្អបានចែងជាច្រើនដង អំពីការដែលព្រះយេស៊ូវបានយាងចេញពីហ្វូងមនុស្ស និងពួកសិស្ស ដើម្បីទៅរកកន្លែងប្រកបជាមួយព្រះវរបិតាយ៉ាងស្ងប់ស្ងាត់។

*ពេលដែលព្រះយេស៊ូវយាងចេញទៅរកកន្លែងអធិស្ឋាន : ម៉ាថាយ ២៦:៣៦*
*ម៉ាកុស ១:៣៥ ៦:៤៦ ១៤:៣២-៣៩ លូកា ៥:១៦ ៦:១២ ៩:១៨*
*១១:១ ២២:៤១ យ៉ូហាន ១៨:១*

បទគម្ពីរម៉ាកុស ១:៣២-៣៩ ក៏បានចែងអំពីរឿងនេះផងដែរ។ ពេលយើងសិក្សាបទគម្ពីរនេះ ឲ្យកាន់តែស៊ីជម្រៅ នោះយើងមើលឃើញសារៈសំខាន់ និងឥទ្ធិពលនៃការប្រកបគ្នា ដែលព្រះអម្ចាស់នៃយើងមានជាមួយព្រះវរបិតា ក្នុងព្រះជន្មរបស់ព្រះអង្គ ហើយយើងក៏រៀនបានការជាច្រើនទៀត។ គឺដូចដែលមានសេចក្តីចែងថា "កាលនៅងងឹតមិនទាន់ភ្លឺស្រាងនៅឡើយ នោះទ្រង់តើនឡើងយាងចេញទៅឯទីស្ងាត់ ហើយអធិស្ឋាននៅទីនោះ"(១:៣៥)។ បន្ទាប់ពីព្រះយេស៊ូវបានធ្វើការប្រោសជម្ងឺ និងបណ្តេញវិញ្ញាណអាក្រក់ចេញពីមនុស្សជាច្រើន អស់ពេលពេញមួយល្ងាចមក(១:២៩-៣៤) ព្រះអង្គបានញែកពេល ដើម្បីប្រកបជាមួយព្រះវរបិតា។ ខ្ញុំជឿថា ត្រង់ចំណុចនេះ ព្រះគ្រីស្ទបានប្រើពេលស្ងាត់ស្ងៀមនោះ ដើម្បីចម្រើនកម្លាំងខាងវិញ្ញាណរបស់ព្រះអង្គឡើងវិញ។

## ការរំខានដែលយើងជួប និងការដឹកនាំរបស់ព្រះ

*"ឯស៊ីម៉ូន និងពួកអ្នកដែលនៅជាមួយ គេក៏ដើរតាមរកទ្រង់ គ្រាបានឃើញទ្រង់ហើយ នោះក៏ទូលថា មនុស្សទាំងអស់កំពុងតែរកទ្រង់ ទ្រង់មានព្រះបន្ទូលតបថា ចូរយើងទៅក្នុងអស់ទាំងភូមិនៅជុំវិញ ដើម្បីឲ្យខ្ញុំបានប្រកាសប្រាប់នៅភូមិទាំងនោះដែរ ដ្បិតគឺដោយហេតុនោះហើយ បានជាខ្ញុំមក"(១:៣៦-៣៨)*



*ព្រះអង្គមិនបានរំពឹងឲ្យយើងដឹកកកាយរកកម្លាំងចិត្ត និងការប្តេជ្ញាចិត្ត ដែលនៅសេសសល់ក្នុងខ្លួនយើងនេះទេ។ ផ្ទុយទៅវិញ យើងត្រូវទូលសូមឲ្យព្រះអង្គប្រទានកម្លាំងរបស់ព្រះអង្គមកយើង និយាយរួម គឺយើងសូមឲ្យព្រះអង្គប្រទានឲ្យយើងមានកម្លាំងឡើង។*

ក្នុងខ.៣៧ គេអាចបកប្រែពាក្យ "*រកឃើញ*" បានម្យ៉ាងទៀតគឺ "តាមរកឃើញ"។ លោកពេត្រុស និងមិត្តភ័ក្ររបស់គាត់បានដឹងច្បាស់ជាងគេ ថាព្រះយេស៊ូវមុខជាបានយាងទៅទីណាហើយ បានជាពួកគេនាំគ្នាទៅរកព្រះអង្គតែម្តង។ ពួកគេបានសម្រេចចិត្តរំខានការអធិស្ឋានរបស់ព្រះអម្ចាស់ ដោយសារការបារម្ភរបស់ខ្លួន នៅពេលដែល "មនុស្សទាំងអស់កំពុងតែរកព្រះអង្គ!"

ប៉ុន្តែ ព្រះយេស៊ូវមិនបានបារម្ភ ខ្លាចគេគិតថាព្រះអង្គមិនអើពើរ ឬមិនយកព្រះទ័យទុកដាក់ចំពោះ

សេចក្តីត្រូវការរបស់ពួកគេឡើយ។ តើការដែលព្រះអង្គចំណាយពេលស្ងាត់ស្ងៀម បានធ្វើឲ្យព្រះអង្គមានការឆ្លើយតបកាន់តែតិច ចំពោះអ្នកដែលនៅក្បែរព្រះអង្គឬ? ផ្ទុយទៅវិញ ដោយសារព្រះអង្គបានចំណាយពេលស្ងាត់ស្ងៀមជាមួយព្រះវរបិតា នោះព្រះអង្គមានព្រះទ័យចង់បន្តបំពេញបេសកកម្ម ដែលធំជាងនោះទៅទៀត គឺ "ស្វែងរក និងសង្គ្រោះមនុស្សបាត់បង់"(លូកា ១៩:១០)។ បើព្រះអង្គបំពេញតែតម្រូវការរបស់អ្នក ដែលនៅចំពោះមុខព្រះអង្គ តើព្រះអង្គមិនត្រូវយកព្រះទ័យទុកដាក់ ចំពោះអស់អ្នកដែលបាត់បង់ផងទេឬ? ការប្តេជ្ញាចិត្តរបស់ព្រះយេស៊ូវមានភាពរឹងមាំ បន្ទាប់ពីព្រះអង្គបានចំណាយពេលជាមួយព្រះវរបិតាហើយ។

***ពេលព្រះយេស៊ូវចំណាយពេលស្ងាត់ស្ងៀម*** *ក្នុងសួនច្បារគេតសេម៉ានី មុនពេលគេយកព្រះអង្គទៅឆ្កាង ព្រះអង្គបានអធិស្ឋានថា "ឱព្រះវរបិតានៃទូលបង្គំអើយ បើសិនជាពែងនេះកន្លងហួសពីទូលបង្គំទៅពុំបាន លើកតែទូលបង្គំទទួលនោះសូមតាមព្រះហឫទ័យទ្រង់ចុះ"(ម៉ាថាយ ២៦:៤២)។*

ព្រះយេស៊ូវបានប្រើពេលស្ងាត់ស្ងៀមជាមួយព្រះវរបិតា ដើម្បីឲ្យមានការប្រកបដ៏មានន័យ ក៏ដូចជា ដើម្បីឲ្យបានទទួលកម្លាំង និងការដឹកនាំ ដើម្បីបំពេញបេសកកម្មរបស់ព្រះអង្គ។ បើសិនជាយើងចង់បានទទួលលទ្ធផលដូចនេះ ពីការចំណាយពេលស្ងាត់ស្ងៀមជាមួយព្រះ យើងចាំបាច់ត្រូវយកគំរូតាមព្រះយេស៊ូវ ហើយអនុវត្តតាមព្រះបន្ទូលព្រះ ដោយអំណាចនៃព្រះវិញ្ញាណ ដោយអនុញ្ញាតឲ្យព្រះបន្ទូលព្រះអង្គជះឥទ្ធិពល មិនគ្រាន់តែមកលើការអ្វីដែលយើងធ្វើទេ តែថែមទាំងកែប្រែជីវិតយើងផងដែរ។

បើយើងចាត់ទុកការចំណាយពេលជាមួយព្រះ ជាការគេចខ្លួនមកសម្រាកខាងវិញ្ញាណមួយថ្ងៃម្តង ឬគ្រាន់តែជាការជៀសចេញពីកិច្ចការជាច្រើន "ដែលត្រូវធ្វើ" នោះយើងអាចធ្លាក់ចូលក្នុងអន្ទាក់ ដែលកាត់ផ្តាច់ជីវិតខាងវិញ្ញាណរបស់យើងចេញពីកិច្ចការដទៃទៀតក្នុងការរស់នៅ។ នេះជាកំហុសមួយ ដែលត្រូវជៀសវាង។ ការចំណាយពេលស្ងាត់ស្ងៀមជាមួយព្រះ ជាជំនួយខាងវិញ្ញាណដែលយើងមិនអាចអត់បាន។ ចាប់តាំងពីសម័យសួនច្បារអេដែន រហូតមកដល់សព្វថ្ងៃនេះ ព្រះសព្វព្រះទ័យនឹងដើរជាមួយរាស្ត្រព្រះអង្គ ក្នុងគ្រប់ផ្នែកទាំងអស់នៃដំណើរជីវិតរបស់ពួកគេ។



*ទីពីរ*

# ការរៀបចំខ្លួន

មនុស្សដែលស្រឡាញ់គ្នាទៅវិញទៅមក មានបំណងចិត្តចង់ចំណាយពេលដ៏មានន័យ ជាមួយគ្នា។ ដើម្បីឲ្យអាចធ្វើដូចនេះបាន គេត្រូវមានការលត់ដំរួមជាមួយសេចក្តីស្រឡាញ់។ ការរកពេល តម្រូវឲ្យមានការរៀបផែនការ ដែលចេញពីចិត្ត។ យ៉ាងណាមិញ ដើម្បីឲ្យយើងមានពេលវេលាដ៏មានន័យជាមួយព្រះ យើងក៏ចាំបាច់ត្រូវមានបំណងចិត្តដូចនេះផងដែរ។ គឺដូចដែលយើងបានឃើញហើយថា ព្រះយេស៊ូវបានធ្វើជាគំរូនៃការប្រកបគ្នា ដែលមានបំណងចិត្ត ដោយព្រះអង្គបានញែកពេលទៅរកកន្លែងស្ងាត់តែអង្គឯង ហើយអនុញ្ញាតឲ្យព្រះអង្គទ្រង់ទទួលប្រយោជន៍ពីពេលស្ងាត់ស្ងៀមនោះ។ ជាញឹកញាប់ ពេលយើងចូលដល់ថ្ងៃថ្មី យើងចង់មានការប្រកបជាមួយព្រះបន្ទូល តាមពេលដែលបានកំណត់ តែពេលវេលាក្នុងថ្ងៃនោះក៏បានរំគិលទៅមុខ យើងមានកិច្ចការមួយហើយមួយទៀតដែលត្រូវធ្វើ និងបានរំខានយើង រហូតដល់ពេលដែលការប្រកបជាមួយព្រះបន្ទូល ត្រូវបានពន្យាពេល ឬត្រូវយើងភ្លេច រហូតដល់ពេលថ្ងៃបន្ទាប់។

ប៉ុន្តែ ពេលដែលយើងផ្តោតអារម្មណ៍ ទៅលើព្រះអង្គជាទីមួយ នោះយើងក៏មានការគិតដ៏ត្រឹមត្រូវ អំពីការអ្វីផ្សេងទៀត ហើយការចំណាយពេលស្ងាត់ស្ងៀមក៏បានក្លាយជាអាទិភាព គឺមិនមែនជាការអ្វីដែលយើងបានប្រញាប់បញ្ចូលក្នុងពេលដែល យើងនៅសេសសល់នោះឡើយ។



*ពេលដែលយើងផ្តោតអារម្មណ៍ ទៅលើព្រះអង្គជាទីមួយ នោះយើងក៏មានការគិតដ៏ត្រឹមត្រូវ អំពីការអ្វីផ្សេងទៀត។*

ការប្រកបគ្នានេះ តម្រូវឲ្យមានការហ្វឹកហាត់លត់ដំ។

ក្នុងបទគម្ពីរ ១កូរិនថូស ជំពូក៩ សាវ័កប៉ុលបាននិយាយប្រៀបប្រដូច អំពីការប្រកួតរបស់កីឡាករ ដើម្បីពន្យល់ អំពីការហ្វឹកហាត់លត់ដំខាងវិញ្ញាណ ដែលយើងត្រូវការ ក្នុងការរស់នៅ។ បទគម្ពីរនេះបានប្រើពាក្យ "ខំអត់សង្កត់ចិត្ត"(ខ.២៥) ដែលតាមន័យត្រង់ គឺមានន័យថា "អំណាចនៃការគ្រប់គ្រងខ្លួនឯង និងការរៀនអត់ធន់"។

*"បានជាខ្ញុំខំរត់យ៉ាងដូច្នោះ មិនមែនបែបដូចជាមិនស្គាល់ផ្លូវទេ ខ្ញុំក៏ខំប្រដាល់យ៉ាងដូច្នោះដែរ មិនមែនដូចជាដាល់ខ្យល់ទេ គឺខ្ញុំវាយដំរូបកាយខ្ញុំ ទាំងបង្ខំឲ្យចុះចូល ក្រែងក្រោយដែលខ្ញុំបានប្រដៅមនុស្សឯទៀតហើយ នោះខ្លួនខ្ញុំត្រូវចោលចេញវិញ(១កូរិនថូស ៩:២៦-២៧)។*

ពេលដែលកីឡាករមានការតាំងចិត្ត ចំពោះការប្រកួតកីឡាអូឡាំពិក ពួកគេជៀសវាងការអ្វីដែលអាចរំខានពួកគេ។ ការហ្វឹកហាត់លត់ដំកាយ និងការតមអាហារដែលមិនត្រូវញ៉ាំ គឺមានសារៈសំខាន់ណាស់។ បើយើងធៀបនឹងជីវិតខាងវិញ្ញាណវិញ យើងអាចទទួលលទ្ធផលដែលមិននឹកស្មានដល់ ពេលដែលយើងរៀនប្រកបជាមួយព្រះបន្ទូលប្រចាំថ្ងៃ ហើយយកការប្រកបនេះជាអាទិភាព ដោយពឹងកម្លាំងរបស់ព្រះ។

ដើម្បីរៀបចំពេលស្ងាត់ស្ងៀម សូមស្វែងយល់អំពីវិធីសាស្ត្រមួយចំនួន ដូចខាងក្រោមនេះ :

**ការរំពឹងគិត ដែលសមហេតុផល** : ខ្ញុំស្គាល់សិស្សសាលាម្នាក់ ដែលពូកែសរសេរអត្ថបទ។ ប៉ុន្តែ គាត់ចេះតែយកកិច្ចការមកប្រគល់ឲ្យគ្រូយឺត ម្តងហើយម្តងទៀត។ គាត់ថា "បើខ្ញុំមិនអាចធ្វើកិច្ចការនោះឲ្យបានល្អឥតខ្ចោះទេ នោះខ្ញុំមិនចង់ធ្វើវាទេ!" ត្រង់ចំណុចនេះ ការដែលគាត់ប្តេជ្ញាចិត្តធ្វើកិច្ចការសាលា ឲ្យបានល្អឥតខ្ចោះ បានបណ្តាលឲ្យគាត់បាត់បង់ពន្ទុះ ជាជាងធ្វើឲ្យមានពន្ទុះល្អជាងមុខ។

យ៉ាងណាមិញ មានមនុស្សជាច្រើនក៏មានការតាំងចិត្តស្រដៀងនឹងគាត់ ដើម្បីរក្សាពេលស្ងាត់ស្ងៀមផងដែរ។ ជាញឹកញាប់ យើងច្រើនតែសម្រេចចិត្តថា "មិនចូលទៅក្នុងពេលស្ងាត់ស្ងៀមទាល់តែសោះតែម្តង" បើសិនជាយើងមិនអាចធ្វើឲ្យបានល្អដូចចិត្ត។

*__ភាពឥតខ្ចោះនិយម__ និងការបង្ខំនៃភាពបន្ទាន់ អាចជាសត្រូវរបស់ពេលស្ងាត់ស្ងៀមជាមួយព្រះ។ ការចំណាយពេលខ្លះជាមួយព្រះ គឺប្រសើរជាងការមិនបានចំណាយពេលជាមួយព្រះអង្គសោះ។*

ប៉ុន្តែ ការប្រកបជាមួយព្រះបន្ទូល មិនមែនជាការអ្វីដែលយើងត្រូវធ្វើឲ្យបានល្អឥតខ្ចោះនោះទេ តែត្រូវធ្វើឲ្យមានការរីកចម្រើនឲ្យកាន់តែល្អឡើង ពីមួយថ្ងៃទៅមួយថ្ងៃ។ យកល្អ យើងគួរមានពេលស្ងាត់ស្ងៀមដ៏ខ្លីជាមួយព្រះ ឲ្យអស់ពីចិត្ត ជាជាងខកខានមិនបានចំណាយពេលជាមួយព្រះអង្គទាល់តែសោះ ដោយសារយើងមិនអាចធ្វើឲ្យបានល្អឥតខ្ចោះ។ យើងកម្រនឹងជួបកាលៈទេសៈ ដែលល្អឥតខ្ចោះ ហើយបើសិនជាយើងរង់ចាំកាលៈទេសៈដ៏ឥតខ្ចោះ នោះយើងប្រហែលជាមិនដែលមានពេលស្ងាត់ស្ងៀម ជាមួយព្រះអង្គឡើយ។



*ការប្រកបជាមួយព្រះបន្ទូល មិនមែនជាការអ្វីដែលយើងត្រូវធ្វើឲ្យបានល្អឥតខ្ចោះនោះទេ តែត្រូវធ្វើឲ្យមានការរីកចម្រើនឲ្យកាន់តែល្អឡើង។*

**រកកន្លែងសមរម្យ ។** សៀវភៅដែលមានចំណងជើងថា សំបុត្រផ្ញើទៅកាន់ម៉ាលខុម ដែលលោកស៊ី អេស លូអ៊ីស(C. S. Lewis)បាននិពន្ធ បានផ្តល់នូវការណែនាំដ៏គួរឲ្យភ្ញាក់ផ្អើលអំពីពេលស្ងាត់ស្ងៀមជាមួយព្រះ។ គាត់បានឲ្យយោបលថា យើងត្រូវប្រាកដថា

យើងទៅរកកន្លែងដែលមិនមានការរំខានពេក គឺមានការរំខានល្មមនឹងអាចជួយឲ្យយើងផ្តោតអារម្មណ៍បានល្អ។ លោកលូអ៊ីសបានដំណាលរឿងរបស់បុរសម្នាក់ដែលបានចំណាយពេលស្ងាត់ស្ងៀមជាមួយព្រះ ក្នុងទូរថភ្លើង ព្រោះគាត់យល់ថាបើគាត់នៅកន្លែងដែលគ្មានសម្លេងរំខានទាល់តែសោះ គឺងាយនឹងនាំឲ្យគាត់ជួបការល្បួងពេក ដែលនាំឲ្យមានអារម្មណ៍វិលវល់។ សម្លេងរថភ្លើងបានបង្ខំឲ្យគាត់ផ្តោតអារម្មណ៍កាន់តែខ្លាំងថែមទៀត។ ដូចនេះ គាត់មានការផ្តោតអារម្មណ៍បានល្អជាងមុខ ពេលដែលមានការរំខានខ្លះៗ។

ត្រង់ចំណុចនេះ យើងត្រូវដឹងថា យើងមិនតែងតែអាចរកបានកន្លែង ដែលមានភាពស្ងាត់ជ្រងំដូចក្នុងរូងភ្នំឡើយ។ យើងចាំបាច់ត្រូវរកកន្លែងណាដែលយើងអាចរកបាន សមតាមតម្រូវការរបស់យើងបំផុត ហើយជួយឲ្យពេលស្ងាត់ស្ងៀមរបស់យើងកាន់តែមានភាពល្អប្រសើរឡើងថែមទៀត។

**ការបំរុងពេលទុកប្រចាំថ្ងៃ :** មនុស្សជាច្រើនបាននិយាយសង្កត់ធ្ងន់ អំពីសារៈសំខាន់នៃការចាប់ផ្តើមថ្ងៃនីមួយៗ ដោយការចំណាយពេលប្រកបជាមួយព្រះបន្ទូល។ មានគ្រីស្ទបរិស័ទម្នាក់ធ្លាប់ប្រាប់ខ្ញុំថា គាត់បានដាក់វិន័យមួយសម្រាប់ខ្លួនឯង គឺ "បើមិនបានអានព្រះគម្ពីរទេ គឺមិនត្រូវញ៉ាំអាហារពេលព្រឹកឡើយ"។ ការប្តេជ្ញាចិត្តនេះ អាចជាអ្វីដែលគាត់ធ្វើកើត ប៉ុន្តែ ការប្រកបជាមួយព្រះបន្ទូល ក៏អាចធ្វើនៅពេលពាក់កណ្តាលថ្ងៃ ឬនៅពេលយប់ជ្រៅបានល្អជាង សម្រាប់អ្នកខ្លះ អាស្រ័យទៅលើទម្លាប់នៃការញ៉ាំអាហារ មុខរបរ ឬរបៀបនៃការរស់នៅរបស់ពួកគេ។ មនុស្សម្នាក់ៗមានស្ថានភាពខុសៗគ្នា។

ព្រះគម្ពីរបានលើកទឹកចិត្តឲ្យយើងជួបជាមួយព្រះ នៅពេលណាក៏បាន ក្នុងថ្ងៃនីមួយៗ។ គឺដូចដែលស្តេចដាវីឌបានថ្លែងក្នុងបទគម្ពីរទំនុកដំកើងថា "ឱព្រះអង្គអើយ ទ្រង់ជាព្រះនៃទូលបង្គំ ទូលបង្គំនឹងស្វែងរកទ្រង់អស់ពីចិត្ត"(ទំនុកដំកើង ៦៣:១)។ ម្យ៉ាងវិញទៀត ទ្រង់ក៏បានមានបន្ទូល អំពីការដែលទ្រង់រំពឹងរង់ចាំពេលជញ្ជឹងគិតព្រះបន្ទូលព្រះ មុនទាំងអស់ទាំង"យាមយប់"(ទំនុកដំកើង ១១៩:១៤៨) ចំណែកឯលោកដានីយ៉ែលវិញ គាត់បានកំណត់ពេលអធិស្ឋាន ដើម្បីប្រកបជាមួយព្រះ មួយថ្ងៃបីដង(ដានីយែល ៦:១០)។ ហើយដើមដំបូងនៃបទគម្ពីរទំនុកដំកើងបាននិយាយអំពីមនុស្សដែលមានពរ ដែល "បានត្រេកអរនឹងក្រឹត្យវិន័យរបស់ព្រះអម្ចាស់"(១:២) ហើយជញ្ជឹងគិតក្រឹត្យវិន័យរបស់ព្រះអង្គ ទាំងយប់ថ្ងៃ"(១:២)។

*មានគ្រីស្ទបរិស័ទជាច្រើនបានបង្កើតទំលាប់**អធិស្ឋាន តាមពេលម៉ោងកំណត់** ដូចជា ក្នុងពេលព្រឹក ពេលពាក់កណ្តាលថ្ងៃ និងពេលល្ងាច ជាវិធីដែលជួយឲ្យខ្លួនលូតលាស់ ហើយលត់ដំការអធិស្ឋានរបស់ខ្លួន ឲ្យកាន់តែមានភាពរឹងមាំ ក្នុងការរស់នៅ។*

ពេលដែលយើងជួបជាមួយព្រះ ជាពេលដែលយើងមានសេរីភាពដ៏អស្ចារ្យ។ វាអាស្រ័យទៅលើការសម្រេចចិត្តរបស់យើង ថាតើពេលណាជាពេលដែលល្អបំផុត សម្រាប់យើងជួបព្រះអង្គក្នុងថ្ងៃនីមួយៗ។ អ្វីដែលសំខាន់នោះ គឺការប្តេជ្ញាចិត្តចំណាយពេលជាប្រចាំថ្ងៃ នៅពេលដែលព្រះអង្គអាចមានបន្ទូលជាមួយអ្នក តាមរយៈព្រះបន្ទូល ហើយអ្នកអាចឆ្លើយតបចំពោះព្រះអង្គដោយការអធិស្ឋាន។

យើងសុទ្ធតែចាំបាច់ត្រូវធ្វើផែនការ ទោះយើងត្រូវការកាលវិភាគដ៏ម៉ឺងម៉ាត់យ៉ាងខ្លាំង ឬគ្រាន់តែត្រូវការកាលវិភាគ ដែលធូរលុងជាងក៏ដោយ។ ចូរប្រើប្រតិទិនព្យួរលើជញ្ជាំង ទូរស័ព្ទស្មាតហ្វូន តារាងធ្វើផែនការប្រចាំថ្ងៃ កំព្យូទ័រ ឬប្រតិទិនប្រភេទផ្សេងទៀត ដើម្បីគូសចំណាំពេលប្រចាំថ្ងៃដែលត្រូវញែក សម្រាប់ជួបព្រះអង្គ។



*ពេលដែលយើងជួបជាមួយព្រះ ជាពេលដែលយើងមានសេរីភាពដ៏អស្ចារ្យ។ វាអាស្រ័យទៅលើការសម្រេចចិត្តរបស់យើង ថាតើពេលណាជាពេលដែលល្អបំផុតសម្រាប់យើងជួបព្រះអង្គ ក្នុងថ្ងៃនីមួយៗ។*

**ការអនុវត្តន៍ខ្លីៗ និងញឹកញាប់ គឺប្រសើរជាងយូរៗម្តង** ៖ មានគ្រូភ្លេងម្នាក់បានមានប្រសាសន៍ថា "ការអនុវត្តន៍ ១៥នាទីក្នុងមួយថ្ងៃ ជារៀងរាល់ថ្ងៃ គឺប្រសើរជាងការអនុវត្តន៍ជាច្រើនម៉ោង ដែលបានតែពីរថ្ងៃ ក្នុងមួយសប្តាហ៍"។

គោលការណ៍មួយនេះ ក៏អាចត្រូវបានយកមកអនុវត្តយ៉ាងងាយ ក្នុងការចំណាយពេលប្រកបជាមួយព្រះបន្ទូលប្រចាំថ្ងៃ។ បានសេចក្តីថា យកល្អ យើងគួរចំណាយពេល១៥នាទី ហើយរក្សាពេលនោះ ជារៀងរាល់ថ្ងៃ ជាជាងបណ្តោយឲ្យមានការស៊ី

បំផ្លាញការលត់ដំប្រចាំថ្ងៃរបស់យើង ដោយការរំខានជាច្រើន រួចព្យាយាមចំណាយពេលដ៏វែងម្តងឬពីរដងក្នុងមួយសប្តាហ៍ជាមួយព្រះអង្គ។ ការចំណាយពេលស្ងាត់ស្ងៀមដែលយើងអាចគ្រប់គ្រងបាន ជួយឲ្យយើងមានទម្លាប់ល្អ ហើយអាចនាំឲ្យយើងមានពេលស្ងាត់ស្ងៀម ដែលញឹកញាប់ ហើយទៀងទាត់ ព្រមទាំងចំណាយពេលនោះបានកាន់តែវែងផង។ ចូរអធិស្ឋាន ដើម្បីសូមឲ្យព្រះអង្គដឹកនាំអ្នក ក្នុងការសម្រេចចិត្តកំណត់រយៈពេល ដែលត្រូវចំណាយ ក្នុងពេលស្ងាត់ស្ងៀម រួចសរសេរអំពីរយៈពេលនោះ ក្នុងប្រតិទិនរបស់អ្នក។



*ទី៣*

# ការអនុវត្តន៍

មិនមែនមានតែការលត់ដំទេ ដែលមានភាពចាំបាច់ ក្នុងពេលស្ងាត់ស្ងៀមរបស់យើង។ ទំនាក់ទំនង ត្រូវបានកសាងឡើង តាមរយៈការទាក់ទងគ្នា ហើយការទាក់ទងគ្នាទៅវិញទៅមក គឺប្រសើរជាងការទាក់ទងតែម្ខាង។

**ព្រះមានបន្ទូលមកកាន់យើង** : កាលពីសម័យមុន ព្រះមានបន្ទូលមកកាន់រាស្ត្រព្រះអង្គដោយផ្ទាល់។ ក្នុងបទគម្ពីរ ១សាំយ៉ូអែល ៣:២១ យើងឃើញថា ព្រះ"បានបើកសម្តែងព្រះអង្គទ្រង់ ដល់លោកសាំយ៉ូអែល តាមរយៈព្រះបន្ទូលព្រះអង្គ"។

ក្នុងព្រះគម្ពីរដើមភាសាហេព្រើ ពាក្យបើកសម្តែង គឺមានន័យថា "បង្ហាញ ឬបើកឲ្យឃើញ"។ ដូចនេះ ព្រះអាទិករបានបើកបង្ហាញ គំនិត បុគ្គលិកលក្ខណៈ និងព្រះទ័យរបស់ព្រះអង្គដល់រាស្ត្ររបស់ព្រះអង្គ។ សព្វថ្ងៃនេះ ព្រះអង្គទំនាក់ទំនងតាមរយៈព្រះគម្ពីរ និងព្រះវិញ្ញាណបរិសុទ្ធ ដែលបំភ្លឺគំនិតយើង ពេលដែលយើងអានព្រះបន្ទូល។

ពេលយើងសិក្សាបទគម្ពីរណាមួយ យើងអាចអនុវត្តតាមលំនាំខាងក្រោម ដើម្បីចំណាយពេលស្ងាត់ស្ងៀម ដោយជំនួយរបស់ព្រះវិញ្ញាណបរិសុទ្ធ ដើម្បីឲ្យការសិក្សាព្រះគម្ពីរមានផលផ្លែល្អ។

ជាដំបូងយើងត្រូវសួរខ្លួនឯងថា : **តើបទគម្ពីរនេះនិយាយអំពីអ្វី?** យើងអាចឆ្លើយសំណួរនេះ ដោយពិនិត្យមើលពាក្យពេចន៍នៃបទគម្ពីរនោះ តាមបរិបទដើមរបស់បទគម្ពីរនោះ។ ចូរអនុញ្ញាតឲ្យបទគម្ពីរ និយាយមកកាន់អ្នក តាមបរិបទប្រវត្តិសាស្ត្រ និងវប្បធម៌នៃបទគម្ពីរនោះ មិនមែនតាមចិត្ត ឬអារម្មណ៍ខ្លួនឯងទេ។

បន្ទាប់មក យើងត្រូវសួរថា : **តើបទគម្ពីរនេះ មានខ្លឹមសារដូចម្តេច?** មិនមែនមានតែមនុស្សសម័យដើមទេ ដែលអាចយល់អំពីអត្ថន័យនៃបទគម្ពីរ។ ក្នុងវគ្គនៃបទគម្ពីរនីមួយៗ គឺមានសេចក្តីពិតស្នូលខាងវិញ្ញាណ ដែលអាចឲ្យយើងយល់បាន ក្នុងគ្រប់សម័យកាល។ យើងគួរតែខិតខំ ស្វែងរកខ្លឹមសារ ដែលបទគម្ពីរមានសម្រាប់យើង នៅថ្ងៃនេះ។

ជាចុងក្រោយ យើងសួរថា : **"តើយើងត្រូវអនុវត្តតាម យ៉ាងដូចម្តេចខ្លះ?"** ព្រះវិញ្ញាណបរិសុទ្ធ អាចកែប្រែគំនិត ពាក្យសម្តី និងអាកប្បកិរិយារបស់យើង ពេលដែលយើងអនុញ្ញាតឲ្យព្រះអង្គប្រើគោលការណ៍ ដែលយើងឃើញមាន ក្នុងព្រះបន្ទូលព្រះ ដើម្បីស្អាងយើងឡើង។ យើងអាចសួរសំណួរខាងលើនេះ បានម្យ៉ាងទៀតថា "តើជីវិតរបស់ខ្ញុំ គួរតែផ្លាស់ប្រែយ៉ាងណា ដោយសារការសិក្សាបទគម្ពីរនេះ?"

*នៅសម័យបុរាណ មាន**វិធីសាស្ត្រលេកទីអូ ឌីវីណា**(Lectio Divina ជាភាសាឡាតាំងមានន័យថា ការអានព្រះគម្ពីរ ដើម្បីស្តាប់ព្រះសូរសៀងព្រះ) ដែលអាចជួយដល់ការអាន និងយល់ព្រះគម្ពីរ។ វិធីសាស្ត្រនេះ ជាការអានព្រះគម្ពីរ រួមជាមួយការអធិស្ឋានយឺតៗ ដោយជញ្ជឹងគិត ដើម្បីស្តាប់ព្រះសូរសៀងព្រះ តាមរយៈព្រះបន្ទូលព្រះអង្គ ដែលមានចែងក្នុងទំព័រព្រះគម្ពីរ។*

**យើងឆ្លើយតបចំពោះព្រះ** : តើអ្នកធ្លាប់សរសេរសំបុត្រមួយច្បាប់ ឲ្យអស់ពីចិត្ត ដោយបើកចំហរដល់ជម្រៅចិត្តរបស់អ្នកឬទេ? តើអ្នកនឹងមានអារម្មណ៍យ៉ាងណា បើសិនជាគេសរសេរសំបុត្រឆ្លើយតបមកវិញ ដោយមិនខ្វល់អំពីពាក្យពេចន៍ដែលអ្នកបានសរសេរក្នុងសំបុត្ររបស់អ្នក ហើយគេនិយាយតែអំពីបញ្ហារបស់ខ្លួនគេប៉ុណ្ណោះ?



*យើងគួរតែសួរថា "តើបទគម្ពីរនេះ សម្រាប់ឲ្យយើងអនុវត្តតាមដូចម្ដេចខ្លះ? តើជីវិតរបស់ខ្ញុំ គួរតែផ្លាស់ប្រែយ៉ាងដូចម្ដេច ដោយសារការសិក្សាបទគម្ពីរនេះ?"*

យ៉ាងណាមិញ ព្រះគម្ពីរជាសំបុត្រនៃក្ដីស្រឡាញ់ ដែលព្រះវរបិតាបានផ្ញើមក។ គឺសំបុត្រដែលនិយាយអំពីជម្រៅនៃសេចក្ដីស្រឡាញ់ ដែលព្រះអង្គមានចំពោះយើង។ ប៉ុន្តែ ជាញឹកញាប់ ទំនាក់ទំនងដែលយើងមានជាមួយព្រះអង្គ ជាទំនាក់ទំនងតែម្ខាង។ បានសេចក្ដីថា យើងអានព្រះរាជសាររបស់ព្រះអង្គ ហើយឆ្លើយតបទៅវិញ ដោយការអធិស្ឋាន ដែលនិយាយតែអំពីខ្លួនឯង។ ត្រង់ចំណុចនេះ យើងមិនបានឆ្លើយតប ចំពោះសំបុត្រនៃក្ដីស្រឡាញ់នោះទេ ផ្ទុយទៅវិញ យើងមិនអើពើចំពោះខ្លឹមសារនៃសំបុត្រ ហើយផ្ដោតទៅលើតែសេចក្ដីត្រូវការ ដ៏អន្ទះសាររបស់ខ្លួនឯងតែប៉ុណ្ណោះ។

ពេលយើងអធិស្ឋាន យើងទូលដល់ព្រះដោយសេរី អំពីការសំខាន់គ្រប់យ៉ាងរបស់យើង។ ប៉ុន្តែ សូមចាំថា ពេលយើងអានព្រះបន្ទូលព្រះអង្គ គឺមានន័យថា យើងកំពុងស្ដាប់ព្រះអង្គមានបន្ទូល អំពីការសំខាន់ដែលព្រះអង្គចង់ឲ្យយើងដឹង។ ដូចនេះ ចូរចំណាយពេលឆ្លើយតប ចំពោះការអ្វីដែលយើងបានអាននោះ។ ចូរអរព្រះគុណព្រះអង្គ សម្រាប់ព្រះបន្ទូលសន្យារបស់ព្រះអង្គ។ ចូរអរសប្បាយនឹងសេចក្ដីបង្រៀន ដែលយើងបានទទួល។ ចូរលន់តួបាប តាមដែលព្រះវិញ្ញាណបណ្ដាលចិត្ត។ ចូរមានចិត្តត្រេកអរ ចំពោះការស្វែងយល់អំពីបុគ្គលិកលក្ខណៈរបស់ព្រះអង្គ។ ចូរទូលសូមឲ្យព្រះអង្គ ជួយឲ្យយើងយល់កាន់តែស៊ីជម្រៅ និងកាន់តែច្បាស់ អំពីអត្ថន័យនៃបទគម្ពីរ និងអំពីអត្ថន័យនៃការផ្លាស់ប្រែ ឲ្យកាន់តែដូចព្រះគ្រីស្ទ។

បទគម្ពីរ ដានីយ៉ែល ៦:១០ បានចែង អំពីលោកដានីយ៉ែល យ៉ាងដូចនេះថា "លោកលុតជង្គង់ចុះអធិស្ឋាន ហើយអរព្រះគុណដល់ព្រះរបស់លោក១ថ្ងៃ៣ដង ដូចជាកាលពីមុន"(ដានីយ៉ែល ៦:១០)។ ពេលដែលលោកដានីយ៉ែលអធិស្ឋានទូលថ្វាយដល់ព្រះ គាត់នៅតែអរព្រះគុណព្រះអង្គ ទោះបីជាស្ថិតក្នុងស្ថានភាពពិបាកយ៉ាងណាក៏ដោយ។ ការអធិស្ឋានរបស់យើង ក៏គួរតែមានការអរព្រះគុណសម្រាប់ការដែលព្រះអង្គធ្វើជាព្រះអម្ចាស់ និងព្រះសង្គ្រោះរបស់យើង និងសម្រាប់ការអ្វីដែលព្រះអង្គបានធ្វើសម្រាប់យើង។

**ចូរសរសេរ** : ពេលយើងកត់ត្រាទុក អំពីការអ្វីដែលយើងបានរកឃើញ ក្នុងពេលស្ងាត់ស្ងៀម យើងអាចតាមដាន ដំណើរនៃក្តីជំនឿរបស់យើង។ យើងនឹងបានឃើញការរីកចម្រើន ក្នុងផ្នែកដែលពិបាកៗ នៃជីវិតយើង ដែលយើងប្រហែលជាមិនបានកត់សំគាល់ឡើយ បើសិនជាមិនបានកត់ត្រាទុកទេនោះ។

អ្នកអាចចម្លងលំនាំខាងក្រោមនេះ ទុកក្នុងសៀវភៅកត់ត្រារបស់អ្នក ហើយចូរកត់ត្រាអំពីពេលស្ងាត់ស្ងៀមប្រចាំថ្ងៃ។

**លំនាំនៃការចំណាយពេលស្ងាត់ស្ងៀម**

កាលបរិច្ឆេទ: ______________________________

បទគម្ពីរ : ______________________________

អ្វីដែលរកឃើញ ក្នុងបទគម្ពីរ : ______________________________

______________________________

______________________________

ការអនុវត្តន៍តាម : ______________________________

______________________________

______________________________

ការអធិស្ឋាន : ______________________________

______________________________

______________________________



*ព្រះយេស៊ូវបានបំពេញ ព្រះរាជកិច្ច នៅលើផែនដី ដូចការដែលមនុស្សទាំងឡាយត្រូវបំពេញកិច្ចការ ថ្វាយព្រះដៃរ និយាយរួម ព្រះអង្គត្រូវពឹងផ្អែកទាំងស្រុងទៅលើព្រះវរបិតា។*

ការអនុវត្តន៍ ដោយការកត់ត្រា ជួយឲ្យយើងចងចាំអំពីការអ្វីដែលយើងបានរៀន ហើយធ្វើឲ្យការទាំងនោះ នៅតែថ្មីក្នុងគំនិតយើង ដើម្បីឲ្យយើងអាចបន្តប៉ះពាល់ចិត្ត ពេញមួយថ្ងៃ។

ព្រះយេស៊ូវជាអង្គបុគ្គល ដែលមានភាពល្អឥតខ្ចោះ តែព្រះអង្គនៅតែស្វែងរកពេល ដែលស្ងាត់ស្ងៀមជាមួយព្រះវរបិតា។ តើហេតុអ្វី? ព្រោះព្រះអង្គបានបំពេញព្រះរាជកិច្ច នៅលើផែនដី ដូចការដែលមនុស្សទាំងឡាយត្រូវបំពេញកិច្ចការ ថ្វាយព្រះដៃរ និយាយរួម ព្រះអង្គត្រូវពឹងផ្អែកទាំងស្រុងទៅលើព្រះវរបិតា។ ព្រះអង្គបានចំណាយព្រះជន្មរបស់ព្រះអង្គនៅលើផែនដីនេះ ដោយការចុះចូលចំពោះព្រះវរបិតាយ៉ាងល្អឥតខ្ចោះ។ ក្នុងទំព័រមុនៗ យើងបានស្វែងយល់ អំពី "ការចំណាយពេលស្ងាត់ស្ងៀម"របស់ព្រះយេស៊ូវ។ ដូចនេះ យើងក៏អាចរៀនសូត្រពីព្រះយេស៊ូវអំពីរបៀបអនុញ្ញាតឲ្យជីវិតយើងទទួលផលប្រយោជន៍ពេញមួយថ្ងៃ ពីការចំណាយពេលស្ងាត់ស្ងៀម។



ទី៤

# អត្ថប្រយោជន៍

បន្ទាប់ពីអ្នកបានចំណាយពេលស្ងាត់ស្ងៀមជាមួយព្រះហើយ តើអ្នកធ្លាប់មានអារម្មណ៍ថា ពេលស្ងាត់ស្ងៀមនោះ ហាក់ដូចជាមិនសូវមានប្រយោជន៍សម្រាប់អ្នក នៅពេលដែលអ្នកចេញទៅក្នុងសង្គមឬទេ? តើពេលវេលា និងការខិតខំ ដែលអ្នកបានចំណាយ ក្នុងការចំណាយពេលជាមួយព្រះបន្ទូល និងការអធិស្ឋាន មិនមានឥទ្ធិពលមកលើបញ្ហារបស់អ្នកឬ? តើការចំណាយពេលស្ងាត់ស្ងៀមជាមួយព្រះ ពិតជាមិនមានសារៈសំខាន់ចំពោះពេលផ្សេងទៀត ក្នុងថ្ងៃនីមួយៗ ដោយពេលទាំងពីរហាក់ដូចជាមិនមានអ្វីទាក់ទងគ្នាទាល់តែសោះមែនឬ? បើអ្នកមានបញ្ហានេះ នោះមានន័យថា អ្នកកំពុងតែដាក់ព្រំដែនកំណត់ជីវិតខាងវិញ្ញាណរបស់អ្នក ឲ្យមានសកម្មភាពតែនៅក្នុងពេលស្ងាត់ស្ងៀមជាមួយព្រះ ក្នុងថ្ងៃនីមួយៗប៉ុណ្ណោះ។ តែព្រះមិនដែលសព្វព្រះទ័យឲ្យយើងរស់នៅបែបនេះឡើយ។ ព្រះអង្គសព្វព្រះទ័យនឹងដើរជាមួយយើង ជាប់ជានិច្ច ដើម្បីជួយយើង ក្នុងការឆ្លងកាត់ការលំបាកប្រចាំថ្ងៃ។

*"ដូច្នេះចូរមានកំឡាំងហើយចិត្តក្លាហានឡើង កុំឲ្យខ្លាច ឬមានសេចក្តីភ័យញ័រចំពោះគេឡើយ ដ្បិតគឺព្រះយេហូវ៉ា ជាព្រះនៃឯង ដែលយាងទៅជាមួយនឹងឯង ទ្រង់មិនដែលខាននឹងប្រោសឯងទេ ក៏មិនដែលលះចោលឯងដែរ"(ចោទិយកថា ៣១:៦)។*

បទគម្ពីរ លូកា ២៤:១៣-៣២ បានចែងអំពីការដែលព្រះយេស៊ូវបានជួបពួកសិស្សពីរនាក់ កំពុងតែដើរតាមផ្លូវទៅស្រុកអេម៉ោស។ បទគម្ពីរនេះ បានបង្រៀនយើង អំពីការសន្ទនាជាមួយព្រះ ក្នុងរយៈពេលពេញមួយថ្ងៃ។

> ក្នុងថ្ងៃដដែលនោះ អ្នកទាំងពីរកំពុងធ្វើដំណើរទៅភូមិអេម៉ោស ដែលមានចម្ងាយប្រហែល១១គីឡូម៉ែត្រ ពីក្រុងយេរូសាឡិម។ ពេលនោះ ពួកគេកំពុងជជែកគ្នា អំពីអ្វីៗដែលបានកើតឡើង។ ខណៈពេលដែលពួកគេកំពុងជជែកគ្នា ព្រះយេស៊ូវក៏បានយាងមក ហើយដើរជាមួយពួកគេដែរ ប៉ុន្តែ ព្រះអង្គបានធ្វើឲ្យពួកគេមិនអាចស្គាល់ព្រះអង្គបាន(លូកា ២៤:១៣-១៦)។

ក្រៅពីការអ្វី ដែលបទគម្ពីរនេះ បានចែងអំពីការធ្វើដំណើររបស់បុរសទាំងពីរ យើងមិនសូវបានដឹងអ្វីផ្សេងទៀត អំពីរឿងនេះឡើយ ប៉ុន្តែ ព្រះគម្ពីរបានបង្ហាញថា កាលនោះ ពួកគេកំពុងមានបញ្ហា។ ពួកគេមានការប៉ះទង្គិចក្នុងចិត្ត ដោយសារការខកចិត្តកាលពីពេលកន្លងមក បានជាពួកគេពិភាក្សាគ្នា។

គឺនៅពេលនោះហើយ ដែលពួកគេកំពុងមានទុក្ខព្រួយ និងការច្របូកច្របល់ក្នុងចិត្ត ហើយព្រះយេស៊ូវក៏បានយាងមកក្បែរពួកគេ។ គឺដូចដែលមានសេចក្តីចែងថា "កាលគេកំពុងតែនិយាយគ្នា ហើយរិះគិតដូច្នេះ នោះព្រះយេស៊ូវក៏ចូលមក យាងជាមួយនឹងគេដែរ"(ខ.១៥)។ រឿងនេះពិតជាអស្ចារ្យណាស់! ព្រះគ្រីស្ទដែលបានមានព្រះជន្មឡើងវិញ បានរួមដំណើរជាមួយពួកគេ។ ដូចនេះ ព្រះអង្គក៏សព្វព្រះទ័យនឹងរួមដំណើរជាមួយយើងផងដែរ។ ជីវិតជាការធ្វើដំណើរ ហើយព្រះគ្រីស្ទសព្វព្រះទ័យ នឹងធ្វើជាអ្នករួមដំណើរជាមួយយើងជាប់ជានិច្ច ពិសេសគឺនៅតាមផ្លូវដែលមានដីហុយ។ ក្នុងដំណើរនៃជីវិតប្រចាំថ្ងៃ យើងប្រហែលជាឈប់សម្រាកនៅតាមផ្លូវយូរៗម្តង ដើម្បីសន្ទនាជាមួយព្រះអង្គ ប៉ុន្តែ ព្រះអង្គសព្វព្រះទ័យឲ្យយើងធ្វើឲ្យបាន

លើសពីនេះទៅទៀត សម្រាប់ព្រះអង្គ។

**ការទទួលស្គាល់ការលំបាកនៃការធ្វើដំណើរ** : ក្នុងការរស់នៅ យើងពិបាកនឹងយល់អំពីរឿងដែលកើតឡើងខុសពីការរំពឹងទុក្ខ និងអំពីភាពអន់ថយ ដែលយើងជួបប្រទះ។ បញ្ហានេះស្ថិតក្នុងចំណោមការពិបាកបំផុត ដែលយើងមានក្នុងជីវិត។ ការភ័ន្តច្រឡំរបស់យើង ច្រើនតែបណ្ដាលមកពីការយល់ដឹងរបស់យើងមានកំណត់ ពោលគឺយើងអាចមើលឃើញរូបភាពតែមួយជ្រុង ក្នុងរូបភាពទាំងមូលនៃបញ្ហា។ បុរសទាំងពីរនាក់ ដែលកំពុងធ្វើដំណើរទៅភូមិអេម៉ោស ក៏កំពុងតែមានបញ្ហាដូចនេះផងដែរ។ ពួកគេមិនគ្រាន់តែបានយល់ដឹង អំពីការជាច្រើនដែលបានកើតឡើង មុនពេលគេចាប់ព្រះអង្គប៉ុណ្ណោះទេ តែថែមទាំងបានដឹងផងដែរ អំពីហេតុការណ៍ដែលបានកើតឡើងបន្ទាប់មកទៀត ដែលខុសពីការរំពឹងទុករបស់ខ្លួន។ ព្រះយេស៊ូវបានជ្រាបអំពីទុក្ខលំបាករបស់ពួកគេ ហើយក៏បានឲ្យពួកគេរៀបរាប់អំពីបញ្ហានោះប្រាប់ព្រះអង្គ។



*ក្នុងការរស់នៅ យើងពិបាកនឹងយល់ អំពីរឿងដែលកើតឡើងខុសពីការរំពឹងទុក្ខ និងអំពីភាពអន់ថយដែលយើងជួបប្រទះ។ បញ្ហានេះស្ថិតក្នុងចំណោមការពិបាកបំផុត ដែលយើងមានក្នុងជីវិត។*

> ព្រះអង្គមានព្រះបន្ទូលទៅគេថា តើរឿងអ្វី ដែលអ្នកនិយាយគ្នា កំពុងដែលដើរទៅ ដោយមានមុខស្រងូតដូច្នេះ ឯម្នាក់ដែលឈ្មោះក្លេវប៉ាស គាត់ឆ្លើយថា តើអ្នកស្នាក់នៅក្នុងក្រុងយេរូសាឡិមតែម្នាក់ឯងទេឬអី បានជាមិនដឹងការដែលកើតមកនៅគ្រានេះ ទ្រង់មានព្រះបន្ទូលថា តើការអ្វីហ្នឹង នោះគេឆ្លើយថា គឺពីដំណើរលោកយេស៊ូវ ពីស្រុកណាសារ៉ែត ជាហោរា ដែលការលោកធ្វើ និងពាក្យសំដីរបស់លោក សុទ្ធតែមានឫទ្ធិ នៅចំពោះព្រះ និងបណ្ដាជនទាំងឡាយផង ហើយពីបែបយ៉ាងណា ដែលពួកសង្គ្រាជ និងពួកនាម៉ឺនយើងខ្ញុំ បានបញ្ជូនលោកទៅ ឲ្យជាប់ទោសដល់ជីវិត ហើយឆ្កាង

លោកផង តែ យើងខ្ញុំបានសង្ឃឹមថា គឺលោកនេះហើយ ជាព្រះដែលរៀបនឹងប្រោសលោះសាសន៍អ៊ីស្រាអែលទាំងប៉ុន្មាន ឥឡូវនេះក៏មានការនេះថែមទៀត ដ្បិតនេះគំរប់៣ថ្ងៃហើយ តាំងពីការទាំងនោះកើតមក ហើយមានស្ត្រីខ្លះក្នុងពួកយើងខ្ញុំបាននាំឲ្យឆ្ងល់ដែរ ដោយបានទៅឯផ្នូរពីព្រលឹម តែរកសពលោកមិនឃើញសោះ ហើយគេមកប្រាប់យើងថា ឃើញទេវតាលេចមកប្រាប់ថា លោករស់ឡើងវិញហើយ មានពួកយើងខ្ញុំខ្លះបានទៅឯផ្នូរដែរ ក៏ឃើញដូចជាពួកស្រីបានថាមែន តែមិនបានឃើញរូបលោកទេ(ខ.១៧-២៤)។



*ពួកគេពិចារណា អំពីជីវិតជាពិសេស អំពីហេតុការណ៍ដែលទើបកើតឡើង ដោយគំនិតដ៏តូចចង្អៀត។ សមត្ថភាពរបស់មនុស្សយើងមានកំណត់ ហើយគ្រាន់តែអាចមើលឃើញរូបភាពតែមួយជ្រុងក្នុងកាលៈទេសៈនីមួយៗ។*

ដូចនេះ ពេលព្រះអង្គសួរអ្នកទាំងពីរ ពួកគេក៏បានរៀបរាប់ជាលម្អិត អំពីការអ្វីដែលបានធ្វើឲ្យពួកគេមានកង្វល់។ និយាយរួម ពួកគេបាននិយាយ អំពីការដែលពួកគេសង្ឃឹមថា ព្រះយេស៊ូវ ពីស្រុកណាសារ៉ែត ជាព្រះម៉ែស៊ី នឹងរំដោះប្រជាជាតិអ៊ីស្រាអែល តែផ្ទុយទៅវិញ ព្រះអង្គបែរជាត្រូវគេយកទៅឆ្កាងសម្លាប់ទៅវិញ។ ដូចនេះ ពេលព្រះអង្គសុគតនៅលើឈើឆ្កាង ក្តីសង្ឃឹមរបស់ពួកគេ និងក្តីសង្ឃឹមរបស់មនុស្សជាច្រើនទៀត ក៏ត្រូវរលាយ។ ពេលដែលគំនិតរបស់ពួកគេកំពុងតែច្របូកច្របល់ស្រាប់ទៅហើយ នោះពួកគេក៏បានទទួលដំណឹងថា ផ្នូររបស់ព្រះអង្គនៅទទេ ហើយមានមិត្តភ័ក្ររបស់ពួកគេមួយចំនួន បានជួប និងបានស្តាប់ពួកទេវតាថ្លែងព្រះរាជសារ។

*យើងមិនមានសមត្ថភាពគ្រប់គ្រាន់ ដើម្បីយល់ដឹងឲ្យបានគ្រប់ជ្រុងជ្រោយ អំពីព្រះនៃយើង ដែលគ្មានដែនកំណត់នោះឡើយ តែយើងមិនត្រូវឈប់ស្វែងរកព្រះអង្គ ដោយសារការខ្វះខាតនេះឡើយ។ ថ្វីដ្បិតតែយើងអាចដឹងអំពីព្រះ មិនបានមួយរយភាគរយមែន តែយើងនៅតែអាចស្គាល់ព្រះអង្គ ហើយព្រះអង្គសព្វព្រះទ័យនឹងមានការប្រកបស្និទ្ធស្នាលជាមួយយើង។*

ពីរបីថ្ងៃក្រោយមក អ្នកទាំងពីរក៏មានសង្ឃឹមឡើងវិញ។ កាលពីមុន ក្ដីស្រម៉ៃរបស់ពួកគេបានរលាយអស់។ ពួកគេបានពិចារណា អំពីជីវិត ជាពិសេស អំពីហេតុការណ៍ដែលទើបកើតឡើង ដោយគំនិតដ៏តូចចង្អៀត។ សមត្ថភាពរបស់មនុស្សយើងមានកំណត់ ហើយគ្រាន់តែអាចមើលឃើញរូបភាពតែមួយជ្រុង ក្នុងកាលៈទេសៈនីមួយៗ។ អ្នកទាំងពីរទទួលយកការអ្វី ដែលខ្លួនបានដឹង មកផ្ទៀងផ្ទាត់នឹងការអ្វីដែលពួកគេបានជួបប្រទះពេលក្រោយមកទៀត ហើយពួកគេមិនបានបន្ថែមបន្ថយឲ្យលើសពីការពិតទេ។ យ៉ាងណាមិញ យើងក៏ធ្លាប់មានបទពិសោធន៍ដូចពួកគេផងដែរ។



*ការយល់ដឹងរបស់យើងមានកំណត់ ដូចនេះ យើងច្រើនតែមិនយល់អំពីការអ្វីដែលយើងបានជឿ។ យើងត្រូវតែចាំថា ការយល់ដឹងរបស់យើងមានកំណត់។*

ការយល់ដឹងរបស់យើងមានកំណត់ ដូចនេះ យើងច្រើនតែមិនយល់ អំពីការអ្វីដែលយើងបានជឿ។ ទោះនោះជាការខកចិត្ត ដោយសារព្រះមិនបានឆ្លើយតបការអធិស្ឋាន តាមការរំពឹងទុករបស់យើង ឬក៏ជីវិតយើងបានជួបរឿងអាក្រក់យ៉ាងណាក៏ដោយ ក៏យើងត្រូវតែចាំថា ការយល់ដឹងរបស់យើងមានកំណត់។

ប៉ុន្តែ ព្រះយេស៊ូវសព្វព្រះទ័យឲ្យយើងទូលព្រះអង្គ អំពីកង្វល់របស់យើង។ ព្រះអង្គបានត្រៀមខ្លួនជាស្រេច ដើម្បីស្ដាប់រាល់ពាក្យពេចន៍ ដែលយើងទូលថ្វាយព្រះអង្គជាលម្អិត ទោះបញ្ហានោះតូច ឬធំក៏ដោយ ក្នុងជីវិតយើង។ ទំនាក់ទំនងដ៏ពិសេស ដែល

គ្រីស្ទបរិស័ទមានជាមួយព្រះគ្រីស្ទ នាំឲ្យខ្លួនមានទំនាក់ទំនងជាមួយព្រះ ដោយការអធិស្ឋាន ទោះជាស្ថិតក្នុងកាលៈទេសៈណាក៏ដោយ។

**ចូរយើងអនុញ្ញាតឲ្យព្រះយេស៊ូវពន្យល់យើង :** អ្នកដើរតាមព្រះយេស៊ូវ មានការតក់ស្លុតយ៉ាងខ្លាំង ពេលដែលក្ដីសង្ឃឹម និងក្ដីស្រម៉ៃរបស់ខ្លួនត្រូវរលាយអស់ ដោយសារពួកគេយល់ថា ខ្លួនបានជួបចុងបញ្ចប់បែបនោះទៅវិញ។ ប៉ុន្តែ ពេលព្រះគ្រីស្ទប្រើបទគម្ពីរ ដើម្បីបំភ្លឺពួកគេឡើងវិញ ពួកគេក៏ចាប់ផ្ដើមមានគំនិតស្រស់ថ្លា អំពីស្ថានភាពរបស់ខ្លួនឡើងវិញ។

> ព្រះអង្គបានមានបន្ទូលទៅពួកគេថា "ឱមនុស្សឥតពិចារណា ហើយក្រនឹងជឿអស់ទាំងសេចក្ដី ដែលពួកហោរាបានទាយទុកមកអើយ តើមិនគួរឲ្យព្រះគ្រីស្ទរងទុក្ខទាំងនោះ ហើយចូលទៅក្នុងសិរីល្អនៃទ្រង់វិញទេឬអី រួចទ្រង់ក៏ស្រាយន័យសេចក្ដី ដែលតម្រូវដល់ទ្រង់ ពីក្នុងគម្ពីរទាំងឡាយ ឲ្យគេស្ដាប់ ចាប់តាំងពីគម្ពីរលោកម៉ូសេ និងគម្ពីរពួកហោរារៀងមក"( លូកា ២៤:២៥-២៧ )។

ត្រង់ចំណុចនេះ ពេលព្រះអង្គមានបន្ទូលថា "ឱមនុស្សឥតពិចារណា" គឺព្រះអង្គកំពុងមានបន្ទូលចំៗតែម្ដង។ ក្នុងព្រះគម្ពីរដើមជាភាសាក្រិក ពាក្យដែលប្រែថា "ឥតពិចារណា" តាមន័យត្រង់ គឺមានន័យថា "មិនដឹងអី"។ ពួកសិស្សទាំងពីរនាក់ ដែលកំពុងធ្វើដំណើរតាមផ្លូវនោះ មិនបានដឹងទាំងស្រុង អំពីដំណើររឿងនោះឡើយ។

*ក្នុងព្រះគម្ពីរដើមភាសាក្រិក ពាក្យដែលប្រែមកថា **"ឥតពិចារណា"** ក្នុងខ.២៥ ក៏ត្រូវបានសាវ័កប៉ុលប្រើ ក្នុងបទគម្ពីរកាឡាទី ជំពូក៣ ខ.១ និងខ.៣ ដែលក្នុងនោះ គាត់បានភ្ជាប់ ភាពល្ងង់ខ្លៅរបស់ពួកគេ ទៅនឹងចំណេះដឹង និងសកម្មភាព។ ភាពល្ងង់ខ្លៅអាចបណ្ដាលមកពីការមិនបានដឹង ហើយក៏អាចបណ្ដាលមកពីបានដឹងហើយ តែមិនធ្វើតាម។*

ពេលនោះ ព្រះយេស៊ូវបានប្រទាននូវដំណោះស្រាយតែមួយគត់ សម្រាប់បញ្ហានេះ គឺផ្ដល់ពណ៌មានជាបន្ថែម។ ព្រះអង្គបានពន្យល់ពួកគេ តាមបទគម្ពីរគន្លឹះ អំពីមូលហេតុដែលពួកគេមិនគួរមានការតក់ស្លុត ចំពោះហេតុការណ៍ដែលបានកើតឡើងកាលពីពីរបីថ្ងៃមុន។ ព្រោះព្រះមែស៊ីត្រូវរងទុក្ខវេទនា មុននឹងត្រូវបានដំកើងឡើងវិញ។



*ជំនឿ និងការយល់ដឹងរបស់យើង នឹងមានការចម្រើនឡើង កាលណាយើងនៅតែបើកចិត្តទូលការបង្រៀន ទោះបីជាស្ថិតក្នុងស្ថានភាពបែបណាក៏ដោយ ហើយបន្តមានទំនាក់ទំនងជាទៀងទាត់ជាមួយព្រះ ដែលជាគ្រូរបស់យើង។*

រឿងនេះបានបង្រៀនយើងថា ទោះយើងមានការពិបាកចិត្ត ដោយសារការខកចិត្តក៏ដោយ ក៏យើងត្រូវដឹងផងដែរថា យើងខ្វះការយល់ដឹង ដែលជួយឲ្យយើងគិតត្រូវ និងអាចយល់អំពីបញ្ហាដែលកើតឡើងនោះ។ ព្រះអម្ចាស់អាចបើកសម្ដែងឲ្យយើងបានដឹងជាបន្ថែមទៀត ដើម្បីជួយឲ្យយើងយល់អំពីស្ថានភាពរបស់យើង។ ប៉ុន្តែ ជួនកាល យើងមិនបានទទួលចម្លើយ រហូតដល់ពេលដែលព្រះគ្រីស្ទយាងមកវិញជាលើកទីពីរ។ ជំនឿ និងការយល់ដឹងរបស់យើង នឹងមានការចម្រើនឡើង កាលណាយើងនៅតែបើកចិត្តទូលការបង្រៀន ទោះបីជាស្ថិតក្នុងស្ថានភាពបែបណាក៏ដោយ ហើយបន្តមានទំនាក់ទំនងជាទៀងទាត់ជាមួយព្រះ ដែលជាគ្រូរបស់យើង។

**ចូររង់ចាំព្រះធ្វើការរបស់ព្រះអង្គ** : កាលណាយើងមានការប្រកបទាក់ទងដ៏មានន័យជាមួយព្រះគ្រីស្ទដែលបានមានព្រះជន្មឡើងវិញ នោះការនេះនាំឲ្យយើងកាន់តែចង់ចំណាយពេលជាមួយព្រះអង្គថែមទៀត។ ពេលអ្នកទាំងពីរដើរទៅដល់គោលដៅរបស់ខ្លួន ពួកគេមានអារម្មណ៍ថា ខ្លួនត្រូវការភាពស្និទ្ធស្នាលជាមួយព្រះសង្គ្រោះ។

> គឺដូចមានសេចក្ដីចែងថា "នោះក៏ជិតដល់ភូមិដែលគេគិតទៅ ហើយទ្រង់ធ្វើដូចជាចង់យាងបង្ហួស តែគេឃាត់ទ្រង់ ដោយពាក្យថា សូមនៅជាមួយនឹងយើងខ្ញុំ

សិន ពីព្រោះល្ងាច ថ្ងៃទាបណាស់ហើយ ដូច្នេះ ទ្រង់ក៏យាងចូលទៅគង់ជាមួយ នឹងគេ"(ខ.២៨-២៩)។

ពួកសិស្សទាំងពីរបានស្តាប់ព្រះអង្គមានបន្ទូល ក្នុងការធ្វើដំណើរអស់ច្រើនគីឡូម៉ែត្រមកហើយ ដោយមិនបានស្គាល់ព្រះអង្គទេ តែពួកគេនៅតែចង់ស្តាប់ព្រះអង្គមានបន្ទូលទៀត។ បានជាពួកគេទទូចថា "សូមនៅជាមួយនឹងយើងខ្ញុំសិន"។ ព្រះអង្គក៏បាននៅញ៉ាំអាហារពេលល្ងាចជាមួយពួកគេ ហើយព្រះវត្តមាននៃព្រះដ៏បរិសុទ្ធ ក៏បានបើកឲ្យការអស្ចារ្យ អាចកើតមានឡើង។ ដូចនេះ **ការរាប់បញ្ចូលព្រះអម្ចាស់ ក្នុងសកម្មភាពទាំងឡាយ នៃការរស់នៅប្រចាំថ្ងៃ** ជាការបើកចំហរទ្វារ ឲ្យព្រះអង្គធ្វើកិច្ចការរបស់ព្រះអង្គ ក្នុងគ្រប់ផ្នែកទាំងអស់នៃជីវិតយើង។

*ការដែលព្រះយេស៊ូវបង្រៀនពួកសិស្សព្រះអង្គ ឲ្យអធិស្ឋាន ជាភស្តុតាងបញ្ជាក់ថា ព្រះអង្គបានយកព្រះទ័យទុកដាក់ចំពោះសកម្មភាពទាំងឡាយ នៃ "ជីវិតប្រចាំថ្ងៃរបស់យើង"។ ពេលពួកគេសូមឲ្យព្រះអង្គបង្រៀនពីរបៀបអធិស្ឋាន ព្រះអង្គក៏បានឆ្លើយតប ដោយប្រាប់ពួកគេឲ្យអធិស្ឋាន គឺមិនគ្រាន់តែអំពីការនៃស្ថានសួគ៌ប៉ុណ្ណោះទេ តែក៏អធិស្ឋានអំពីបញ្ហាដែលកើតមានជាធម្មតា ក្នុងថ្ងៃនីមួយៗ ដូចជា បញ្ហាហូបចុក និងការអត់ទោសជាដើម(ម៉ាថាយ ៦:៨-១៥ លូកា ១១:១-៤)។*

កាលគង់នៅតុជាមួយគ្នា នោះទ្រង់យកនំបុ័ងមកប្រទានពរ រួចកាច់ប្រទានទៅឲ្យគេ នោះភ្នែកគេបានបើកភ្លឺឡើង ហើយគេបានស្គាល់ទ្រង់ តែទ្រង់បាត់ពីមុខគេទៅភ្លាម នោះគេនិយាយគ្នាថា "តើយើងមិនមានសេចក្តីខ្នួលខ្នាញ់នៅក្នុងចិត្ត ក្នុងពេលដែលទ្រង់កំពុងតែមានព្រះបន្ទូលនឹងយើង ហើយសំដែងពីគម្ពីរតាមផ្លូវនោះទេឬអី"(លូកា ២៤:៣០-៣២)។

ពេលដែលព្រះយេស៊ូវយកនំបុ័ងមកប្រទានពរ រួចកាច់ប្រទានទៅឲ្យគេ នោះភ្នែកគេបានបើកភ្លឺឡើង ហើយគេបានស្គាល់ទ្រង់។ មុននោះ "ភ្នែកគេត្រូវបិទ្ធឹន មិនឲ្យស្គាល់ទ្រង់ទេ" (ខ.១៦)។ តែពេលនេះ ពួកគេដឹងថា អ្នកដែលបានរួមដំណើរជាមួយខ្លួនជានរណាហើយ ពួកគេទំនងជាមានការភ្ញាក់ផ្អើលនឹងការដែលព្រះអង្គបើក

បង្ហាញព្រះអង្គទ្រង់ភ្លាមៗ ហើយក្រោមក ក៏បាត់ពីមុខគេទៅ បានជាអ្នកទាំងពីរបាននិយាយឆ្លុះបញ្ចាំងអំពីអារម្មណ៍ដែលពួកគេមាន ក្នុងការដើរជាមួយព្រះអង្គ ហើយបានទទួលការបង្រៀនព្រះគម្ពីរ ពីព្រះអង្គ។ ចិត្តរបស់ពួកគេក៏បានឆេះឆួលឡើង ពេលដែលព្រះអង្គពន្យល់បទគម្ពីរ ដោយការយល់ដឹងមកពីស្ថានសួគ៌ និងដោយអំណាច។ ក្នុងព្រះគម្ពីរដើមភាសាក្រិក ពាក្យដែលប្រែមកថា ភ្នែកពួកគេ "បានភ្លឺឡើង" ក្នុង(ខ.៣១) ត្រូវបានប្រើ ដើម្បីពន្យល់អំពីការដែលព្រះយេស៊ូវ "សម្តែង" ព្រះគម្ពីរដល់ពួកគេ (ខ.៣២)។ មានន័យថា ព្រះអង្គបានទំលុះគំនិតរបស់ពួកគេ ឲ្យបើកឡើង ដើម្បីទទួលការសម្តែងព្រះបន្ទូល ឲ្យមានការយល់ដឹង។



*ការមើលឃើញព្រះគ្រីស្ទ ក្នុងព្រះគម្ពីរ និងក្នុងសកម្មភាពទាំងឡាយ ជាប្រចាំថ្ងៃ គួរតែកើតមានពេញមួយថ្ងៃ ជាជាងការកំណត់ឲ្យមានតែមួយថ្ងៃម្តង។*

ការមើលឃើញព្រះគ្រីស្ទ ក្នុងព្រះគម្ពីរ និងក្នុងសកម្មភាពទាំងឡាយ ជាប្រចាំថ្ងៃ គួរតែកើតមានពេញមួយថ្ងៃ ជាជាងការកំណត់ឲ្យមានតែមួយថ្ងៃម្តង។

ការកសាងទំនាក់ទំនង មិនមែនជាការងាយស្រួលទេ។ យើងត្រូវមានភាពឧស្សាហ៍ព្យាយាម ការលត់ដំ ការទំនាក់ទំនង ការអត់ធ្មត់ ទំនុកចិត្ត និងពេលវេលា។ ទំនាក់ទំនងជាមួយព្រះ ក៏ត្រូវមានលក្ខណៈទាំងនេះផងដែរ។ សៀវភៅនេះត្រូវបាននិពន្ធឡើង ដើម្បីផ្តល់នូវក្តីសង្ឃឹម ការបញ្ចេះចិត្ត និងការធ្វើផែនការ សម្រាប់ប្រកបស្និទ្ធស្នាលជាមួយព្រះ ជាទៀងទាត់។ **ចូរចំណាយពេលជាមួយព្រះអង្គ ក្នុងព្រះបន្ទូល និងក្នុងការអធិស្ឋាន។ ចូរសន្ទនាជាមួយព្រះអង្គ ក្នុងគ្រប់ផ្នែកទាំងអស់ នៃជីវិតប្រចាំថ្ងៃរបស់អ្នក។ ចូរអនុញ្ញាតឲ្យព្រះអង្គមានបន្ទូលមកកាន់អ្នក ហើយចំណាយពេល**

**និយាយទៅកាន់ព្រះអង្គ ឲ្យបានញឹកញាប់។** កាលណាអ្នកបានធ្វើដូចនេះហើយ ជីវិតដែលមានការប្រកបស្និទ្ធស្នាលជាមួយព្រះ នឹងមានការលូតលាស់ ហើយកាន់តែស៊ីជម្រៅហើយពេលដែលអ្នកបានទទួលលទ្ធផលល្អដូចនេះហើយ អ្នកនឹងបានដឹងថា ការខិតខំរបស់អ្នកគឺមិនឥតប្រយោជន៍សោះឡើយ។

# ក្រុមសៀវភៅការរុករកឃើញ

*ការងារបេសកកម្មរបស់យើងខ្ញុំ គឺដើម្បីឲ្យមនុស្សគ្រប់រូបមានឱកាសទទួល និងមានការយល់ដឹងអំពីប្រាជ្ញានៃព្រះគម្ពីរ ដែលធ្វើឲ្យជីវិតផ្លាស់ប្រែ ។*

ក្រុមសៀវភៅការរុករកឃើញ បកស្រាយអំពីសេចក្ដីពិតនៃព្រះយេស៊ូវគ្រីស្ទដល់លោកិយ ដោយប្រើធនធានដែលមានគុណភាព ដែលគួរឲ្យចាប់អារម្មណ៍ និងអាចរកបាន ដែលបង្ហាញថា ព្រះគម្ពីរមានសារៈសំខាន់បំផុតចំពោះគ្រប់ផ្នែកទាំងអស់នៃជីវិត។ កូនសៀវភៅ នៅក្នុងក្រុមសៀវភៅការរុករកឃើញ គឺអាចរកបាន ដោយឥតគិតថ្លៃ ហើយអាចត្រូវបានប្រើសម្រាប់ការសិក្សាផ្ទាល់ខ្លួន ក្នុងក្រុមតូច ឬក្នុងការងារឃោងចាប់។

យើងខ្ញុំសូមអរគុណ សម្រាប់ការគាំទ្រធនធានរបស់ក្រុមសៀវភៅការរុករកឃើញ និងអង្គការនំម៉ាណាប្រចាំថ្ងៃ។ មានគ្រីស្ទបរិស័ទជាច្រើនបានរួមចំណែកក្នុងការដាក់ដង្វាយឧបត្ថម្ភ ទោះតិចតួច ឬច្រើនក្ដី ដល់អង្គការនំម៉ាណាប្រចាំថ្ងៃ ដើម្បីឲ្យឃោងចាប់អ្នកដទៃ ដោយប្រាជ្ញានៃព្រះគម្ពីរដែលធ្វើឲ្យជីវិតផ្លាស់ប្រែ។ យើងខ្ញុំមិនបានទទួលប្រាក់ជំនួយពីក្រុម ឬនិកាយណាមួយឡើយ។